ល្បែងកម្សាន្ត

# ប៉ះ រួចអរគុណ

ព្រះគម្ពីរបង្រៀនយើងឲ្យមានអំណរគុណ ( សូមមើល ទំនុកដំកើង ១០០:៤ ) ។ អ្នកអាចមានភាពសប្បាយរីករាយ *និង* មានអំណរគុណនៅពេលអ្នកលេងល្បែងនេះ !



១. សូមរកកន្លែងទូលាយដើម្បីអ្នកអាចរត់ចុះឡើង ។ សូមរើសកន្លែងមួយដើម្បីធ្វើជា « កន្លែងដើម្បីថ្លែងអំណរគុណ » ។

២. មនុស្សគ្រប់គ្នាអាចដាក់ដៃប៉ះគ្នាទៅវិញទៅមក ! ពេលដែលគេប៉ះអ្នក នោះ សូមដាក់ដៃនៅកន្លែងដែលគេប៉ះ ។ អ្នកអាចប៉ះអ្នកផ្សេងទៀតដោយប្រើដៃម្ខាងទៀត ។

៣. នៅពេលគេប៉ះអ្នកជាលើកទីពីរ សូមដាក់ដៃ ម្ខាងទៀតរបស់អ្នកនៅកន្លែងដែលគេប៉ះ ។

៤. នៅពេលគេប៉ះអ្នកនៅ*លើកទីបី*សូមទៅទីតាំងថ្លែងអំណរគុណហើយនិយាយអ្វីបីយ៉ាងដែលអ្នកមានអំណរគុណ ។ ខណៈដែលអ្នកបាននិយាយរឿងទាំងបីនោះអ្នកអាចលែងល្បែងនេះម្តងទៀតបាន ។

រចនារូបភាពដោយ ស្តេហ្វានី ម៉ាកខាលវី

តើអ្នកគិតថាសត្វកវែងនេះនិយាយអ្វី ? សូមសរសេរប្រាប់យើង ! សូមបើកទៅទំព័រខាងក្រោយដើម្បី មើល ។



